# ពុទ្ធសាសនា

## រួងរឿង ឬ រោយរៀន


រៀបរៀងដោយ

**ភិក្ខុ ចិន តេន ឥន្ទបញ្ញោ**

វត្តពោធិវង្ស ប្រទេសបារាំង



**ព.ស.២៥៤៦ គ.ស.២០០២**

*ជាតិនិងសាសនា នៅកម្ពុជា ប៉ះពារទុក្ខភ័យ*
*កូនចៅជាតិខ្មែរ ត្រូវតែលកលៃ កំចាត់ទុក្ខភ័យ*
***តាមន័យព្រះធម៌ ។***

រាល់សៀវភៅដែលខ្ញុំរៀបរៀង
អាចបោះពុម្ពចែកជាធម្មទានបាន
ដោយមិនចាំបាច់សុំអនុញ្ញាតឡើយ។

*បើមានកំហុសឆ្គងក្នុងការវាយពុម្ពអក្សរនេះ សូមលោកអ្នកអានមេត្តាជួយកែលម្អឲ្យបានត្រឹមត្រូវឡើងវិញផង*

*អរគុណ* !!!

**ម.ឧត្តម**

២៥/១០/២០១៣

# អារម្ភកថា

ខ្ញុំមានការព្រួយប្រារព្ធច្រើន មិនដឹងជាក្នុងអនាគតពុទ្ធសាសនានឹងទៅជាយ៉ាងណា រុងរឿងឡើងវិញឬក៏រោយរៀវចុះតទៅទៀត។ ចាស់ៗ តំណាលថា ចាប់ពីពាក់កណ្ដាលពុទ្ធសាសននាទៅ ពុទ្ធាសាសនានឹងចំរើនឡើងវិញ តើយកគោលអ្វីធ្វើពាក់កណ្ដាល ? បើរាប់ពី ព.ស.២៥០០ មក ឃើញមានពុទ្ធសាសនាផ្សាយរីកទៅកាន់ប្រទេសផ្សេងៗច្រើនដែរ បើមើលការបដិបត្តិរបស់ព្រះសង្ឃ ឃើញដូចជារួមចុះ ប៉ុន្តែបើមើលការផ្សាយខាងសមថៈវិបស្សនា ដូចជារីកឡើងវិញ គួរឱ្យជ្រះថ្លា នឹងមានសង្ឃឹមខ្លះដែរ។

យ៉ាងណាក៏ដោយខ្ញុំជឿថា ពុទ្ធាសាសនារុងរឿងឬរោយរៀវមកពីមនុស្សធ្វើ បើគេធ្វើតាមហេតុដែលនាំឱ្យរុងរឿង វារុងរឿង បើគេធ្វើហេតុនាំរោយរៀវ វារោយរៀវ។ ដូចនេះ យើងត្រូវជៀសវាងហេតុរោយរៀវ ហើយដើរតាមហេតុរុងរឿង តែប៉ុណ្ណឹងក៏ចប់កិច្ចហើយ។

វត្តពោធិវង្ស, ថ្ងៃទី ៨ តុលា ព.ស.២៥៤៦

**ភិក្ខុ ខិន ភេន ឥន្ទបញ្ញោ**

# ពុទ្ធសាសនា
# រុងរឿង ឬ រោយរៀវ

---

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៕**

## សភាពធម្មតា

អ្វីដែលកើតមានហើយ ជាមនុស្សក្តី ជាសត្វក្តី ឬជាអ្វីក៏ដោយ ទោះបីមានវិញ្ញាណក្តី មិនមានវិញ្ញាណក្តី សូម្បីមិនមានរូបគ្រប់គ្រាន់តែជាស្ថាប័នឬជាអង្គការអ្វីមួយក្តី បើកើតបើមានហើយ មិនស្ថិតនៅដូចដើមដដែលទេ តែងតែប្រែប្រួលជាធម្មតា។

ខាងដើម វាប្រែប្រួលឡើង (អបាកដជរា) ចេះតែចំរើនឡើងៗ រហូតដល់ពេញកម្លាំង ត្រង់កណ្តាល វាស្ថិតនៅជាសភាពពេញកម្លាំងនោះ មួយរយៈខាងក្នុងវាចាប់ប្រែប្រួលចុះ(បាកដជរា)ចុះទៅៗរហូតដល់រលត់(មរណៈ)។ អ្វីដែលមានជីវិត ដូចមនុស្សជាដើមបើដល់ពេកប្រែប្រួលចុះហើយ វាចេះតែចុះរហូតដល់ចប់ ឥតមានត្រឡប់បានទេ ប៉ុន្តែអ្វីដែលជាស្ថាប័នឬជាអង្គការ វាអាចប្រែឡើង ប្រែចុះបានច្រើនសាតាមហេតុបច្ច័យ តែក៏ត្រូវចប់ក្នុងទីបំផុតដូចគ្នា គ្រាន់តែយូរយារជាងគ្នាតែប៉ុណ្ណោះ នេះជារឿងធម្មតា ។



## ស្ថាប័នពុទ្ធសាសនា

ពុទ្ធសាសនាជាស្ថាប័នមួយ កើតឡើងដោយសាការត្រាស់ដឹង និងការផ្សព្វផ្សាយរបស់ព្រះពុទ្ធ។ ពុទ្ធសាសនានេះ មានការរីកចំរើនរុងរឿងខ្ពស់បំផុត ទាំងផ្នែកការចេះដឹង និងផ្នែកការបន្ទុះមគ្គផល ដល់គោលដៅរបស់សាសនា ក្នុងសម័យដែលព្រះសម្មាសម្ពុទ្ធ គង់ព្រះជន្មនៅឡើយ ប៉ុន្តែក្នុងពេលនោះ មិនទាន់មានការផ្សព្វផ្សាយព្រះពុទ្ធសាសនា ទៅកាន់នានាប្រទេសនៅឡើយទេ។

ទើបតែក្នុងសម័យព្រះបាទអសោកមហារាជ ព្រះអង្គជាមហាអគ្គសាសនូបត្ថម្ភក៏ទ្រង់បានដឹកនាំប្រជារាស្ត្របដិបត្តិធម៌វិន័យយ៉ាងគគ្រឹកគគ្រេង ហើយព្រះអង្គចំណាយព្រះរាជទ្រព្យសន្ធឹកសន្ធាប់ណាស់ទំនុកបម្រុងពុទ្ធសាសនាព្រមទាំងបានបញ្ជូនសមណទូតទៅប្រកាសផ្សព្វផ្សាយពុទ្ធសាសនា នៅនានាប្រទេសជាច្រើនទៀតផង ពុទ្ធសាសនានៅពេលនោះមានពន្លឺរស្មីសម្បើមណាស់ដែរ ប៉ុន្តែក្រោយសម័យនោះ ពុទ្ធសាសនាក៏ចុះអន់ថោយទៅវិញ។

ចំណែកព្រះពុទ្ធសាសនា នៅនានាប្រទេស ក៏បានរីកស្គុះស្គាយគួរជាទីជ្រះថ្លាដែរ តែសម័យកុម្មុយនិស្ត ព្រះពុទ្ធសាសនាក៏រងគ្រោះថ្នាក់សន្ធឹកសន្ធាប់ ចុះអាប់អោនថយយ៉ាងខ្លាំង។ សព្វថ្ងៃខាងបរិមាណ ពុទ្ធសាសនា បានរីកដុះដាលផ្សាយទៅកាន់ប្រទេសផ្សេងៗជាច្រើនថែមទៀត ប៉ុន្តែខាងគុណភាព(ការបដិបត្តិ)មានការធ្លាក់ចុះជាលំដាប់ គួរឲ្យព្រួយបារម្ភ។ បើយើងដេកលក់ ឬរងចាំព្រេងសំណាង មុខជាអន្តរាយជាពុំខាន។ ដូចនេះយើងអ្នកកាន់ពុទ្ធសាសនា ត្រូវភ្ញាក់រលឹក សិក្សា ពិនិត្យ ពិចារណា ឲ្យល្អិតល្អន់ម៉តចត់ល្អ តើមានហេតុ មានបច្ច័យអ្វីដែលយើងត្រូវធ្វើ ដើម្បីសេចក្តីចុំចើ្តងរុងរឿងនៃព្រះពុទ្ធសាសនារបស់យើងតអង្វែងទៅ។ ក្នុងលោកនេះគ្មានសាសនាណាមានសច្ចធម៌ ធម៌ពិតមែន ដូចពុទ្ធសាសនាទេ គ្មានសាសនាណាមានពាក្យប្រៀនប្រដៅមានហេតុមានផលស្រដៀងគ្នាវិទ្យាសាស្ត្រដូចពុទ្ធសាសនាទេ គ្មានសាសនាណាមានពាក្យប្រៀនប្រដៅសម្បូណ៌បែបដើម្បីប្រយោជន៍ទាំងពាគីប្រយោជន៍ក្នុងស្រុកមនុស្ស ទេវតា និងព្រះនិព្វាន ដូចព្រះពុទ្ធសាសនាទេ។

## ធម៌ធ្វើឲ្យព្រះសទ្ធម្មស្ថិតស្ថេរ

ក្នុងគម្ពីរ សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត ព្រះពុទ្ធបានសម្តែងធម៌ដែលនាំឲ្យព្រះសទ្ធម្មស្ថិតស្ថេរ ៥ យ៉ាង ទុកជា ៣ បែប គឺ៖

ធម៌ ៥ យ៉ាង បែបទី ១ គឺ៖

១.ភិក្ខុ សក្កច្ចំ ធម្មំ សុណន្តិ ភិក្ខុទាំងឡាយស្តាប់ធម៌ដោយគោរព។
២.សក្កច្ចំ ធម្មំ បរិយាបុណន្តិ ភិក្ខុទាំងឡាយរៀនធម៌ដោយគោរព។
៣.សក្កច្ចំ ធម្មំ ធារេន្តិ ភិក្ខុ ទាំងឡាយទ្រទ្រង់(ចាំ)ធម៌ដោយគោរព។

៤.សក្កច្ចំ ជតានំ ជម្មានំ អត្ថំ ឧបបរិក្ខន្តិ ភិក្ខុទាំងឡាយពិចារណាអត្ថនៃធម៌ដែលខ្លួនទ្រទ្រង់ហើយដោយគោរព។

៥.សក្កច្ចំ អត្ថមញ្ញាយ ជម្មមញ្ញាយ ជម្មានុជម្មំ បដិបជ្ជន្តិ ភិក្ខុទាំងឡាយដឹងអត្ថដឹងធម៌បដិបត្តិតាមសមគួរដល់ធម៌ដោយគោរព។

### ធម៌ ៥ យ៉ាង បែបទី ២ គឺ៖

១.ភិក្ខុទាំងឡាយរៀនធម៌គឺ សុត្ត គេយ្យ វេយ្យាករណ គាថា ឧទាន ឥតិវុត្តក ជាតក អព្ភុតជម្ម វេទល្ល (បានសេចក្តីថា រៀនធម៌ គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគ្រប់មុខ) ។

២.ភិក្ខុទាំងឡាយ សម្តែងធម៌ តាមដែលបានស្តាប់បានរៀនមកដល់បុគ្គលដទៃដោយពិស្តារ។

៣.ភិក្ខុទាំងឡាយបង្រៀនធម៌... ដោយពិស្តារ។

៤.ភិក្ខុទាំងឡាយស្វាធ្យាយធម៌... ដោយពិស្តារ។

៥.ភិក្ខុទាំងឡាយត្រិះរិះធម៌រឿយៗ ពិចារណារឿយៗ ជញ្ជឹងរឿយៗ ក្នុងចិត្តនូវធម៌ដែលបានស្តាប់មកបានរៀនមក។

### ធម៌ ៥ យ៉ាង បែបទី ៣ គឺ៖

១.ភិក្ខុទាំងឡាយរៀនព្រះសូត្រដោយបទនិងព្យញ្ជនៈបានត្រឹមត្រូវរមែងយល់សេចក្តីបានងាយ។

២.ភិក្ខុទាំងឡាយជាអ្នកប្រដៅងាយ អត់ធន់ និងទទួលពាក្យប្រៀនប្រដៅដោយគោរព។

៣.ភិក្ខុទាំងឡាយជាអ្នកចេះដឹងធម៌វិន័យច្រើនហើយខំបង្រៀនដល់ភិក្ខុដទៃ ដើម្បីកុំឲ្យបាត់បង់។

៤.ភិក្ខុទាំងឡាយជាថេរៈ មិនល្មោភលាភសក្ការៈជាអ្នកបដិបត្តិតឹងរឹង ជាអ្នកនាំមុខក្នុងវិវេក(សមថវិបស្សនា)ដើម្បីឲ្យបានសម្រេចធម៌កាន់តែខ្ពស់ឡើងៗ ជាទិដ្ឋានុគតិដល់សិស្សជំនាន់ក្រោយ។

៥.ព្រះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា...ប្រជាជនដែលមិនទាន់ជ្រះថ្លា រមែងជ្រះថ្លាឡើង ដែលជ្រះថ្លាស្រាប់ហើយក៏រឹតតែជ្រះថ្លាឡើងទៀត។

ធម៌ ៥ យ៉ាងទាំង៣បែបនេះបើយើងរួមបញ្ចូលគ្នានឹងបានជាគោលធម៌ធ្វើឲ្យព្រះសទ្ធម្មស្ថិតស្ថេរ ៧ ប្រការគឺ៖

១.ត្រូវរៀនធម៌វិន័យឲ្យសព្វគ្រប់ ហើយត្រឹមត្រូវ និងពិស្តារ។

២.ត្រូវបង្រៀន និងសម្តែងធម៌វិន័យឲ្យត្រឹមត្រូវ និងពិស្តារ។

៣.ត្រូវពិចារណាអត្ថន័យ នៃព្រះធម៌ដែលបានរៀនមកឲ្យត្រឹមត្រូវ។

៤.ត្រូវបដិបត្តិធម៌ ឲ្យសមគួរដល់ធម៌គឺ ធម៌នេះ មានកម្រិតយ៉ាងណា ត្រូវបដិបត្តិឲ្យដល់កម្រិតនោះឬបុគ្គលប្រភេទនេះ មានធម៌ត្រូវបដិបត្តិយ៉ាងណា ត្រូវបដិបត្តិឲ្យដល់កម្រិតធម៌របស់បុគ្គលប្រភេទនោះ។

៥.ត្រូវជាអ្នកប្រដៅងាយ អត់ធន់ ទទួលពាក្យប្រៀនប្រដៅដោយគោរព មិនដណ្តើមធំគ្រប់គ្នា។

៦.ព្រះថេរៈ គប្បីជាអ្នកមិនល្មោភលាភសក្ការៈ ជាអ្នកបដិបត្តិមិនបន្ធូរបន្ថយ ជាអ្នកនាំមុខក្នុងវិវេក(សមថវិបស្សនា)។

៧.ព្រះសង្ឃត្រូវព្រមព្រៀមគ្នា សេចក្តីព្រមព្រៀមនៃសង្ឃ រមែងញុំាងជនមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង និងញុំាងជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាថែមទៀត។



## ហេតុបច្ច័យនាំឲ្យរុងរឿង និងរីកចំរើន នៃ ពុទ្ធសាសនា

១.ព្រះពុទ្ធ អ្នកបង្កើតពុទ្ធសាសនា ព្រះអង្គមានបុណ្យបារមីច្រើន ប្រកបដោយព្រះបញ្ញាគុណ ព្រះវិសុទ្ធិគុណ និងព្រះមហាករុណាទិគុណដ៏លើសលប់ គ្មានបុគ្គលណាប្រៀបផ្ទឹមបាន។

២.វិធីដំណើរការដ៏ប៉ិនប្រសប់របស់ព្រះអង្គគឺ៖

ក.ការផ្សព្វផ្សាយ

ខ.ការសិក្សា

គ.ការបដិបត្តិ

ឃ.ការគ្រប់គ្រង

ង.ការសាងសង់

បន្ទាប់ពីបានត្រាស់ដឹង ការផ្សព្វផ្សាយសាសនាជាទី១ គឺ ព្រះអង្គស្តេចទៅផ្សាយសាសនា ពេលបានជួបនឹងបញ្ចវគ្គីយ៍ ព្រះអង្គឲ្យសិក្សាជាទី២ និងឲ្យបដិបត្តិជាទី៣ ពេលដែលបញ្ចវគ្គីយ៍ភិក្ខុ បានសម្រេចមគ្គផលហើយ ព្រះអង្គបញ្ជូនឲ្យទៅជួយផ្សាយសាសនាភ្លាម ព្រោះការផ្សាយនេះជារឿងសំខាន់ណាស់។ ក្រោយពេលដែលព្រះសង្ឃកើតឡើងច្រើនហើយទើបព្រះអង្គចាត់ការគ្រប់គ្រងដោយយកធម៌វិន័យជាធំ។ ចំណែកការសាងសង់ជាកិច្ចក្រោយបំផុត គឺព្រះអង្គចាត់ចែងឲ្យមានព្រះសង្ឃចូលរួមចំណែកក្នុងវនកម្មតាមសមគួរ។

៣.អ្នកចូលមកបដិបត្តិធម៌ជាមួយនឹងព្រះអង្គ គឺជាអ្នកមានសទ្ធាជ្រះថ្លា បដិបត្តិពិតប្រាកដម៉ត់ចត់ត្រឹមត្រូវ ដោយឡែកគឺ ព្រះសង្ឃសាវកជារៀមច្បង លោកបដិបត្តិប្រពៃបដិបត្តិត្រង់ ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក។

៤.អ្នកដឹកនាំប្រទេសជាតិ ព្រះបាទពិម្ពិសារ បសេនទិកោសល្យរហូតដល់ អសោកមហារាជជាដើម លោកជួយឧបត្ថម្ភនិងការពារក្នុងពេលដែលសាសនាឯទៀតគេបៀតបៀន។

កាលបើធម៌ ឬហេតុបច្ច័យ នាំឲ្យចំរើនរុងរឿងមានព្រមសេចក្តីចំរើនរុងរឿងក៏មានដែរ បើហេតុប្រែប្រួល ផលក៏ត្រូវតែប្រែប្រួលទៅតាមហេតុនោះដែរ នេះជាច្បាប់ធម្មតា។ មិនមែនមានតែធម៌ឬ ហេតុបច្ច័យនាំឲ្យព្រះសទ្ធម្មឬសាសនាចំរើនរុងរឿងប៉ុណ្ណោះទេ ធម៌ឬហេតុបច្ច័យដែលនាំឲ្យវិនាសសាបសូន្យក៏មានដែរ ដែលនឹងលើកយកមកជម្រាបដូចតទៅនេះ៖

## **ធម៌ ៥ យ៉ាង នាំឲ្យព្រះសទ្ធម្មសាបសូន្យ គឺ ÷**

១.ភិក្ខុ ន សក្កច្ចំ ធម្មំ សុណន្តិ ភិក្ខុទាំងឡាយមិនស្តាប់ធម៌ ដោយគោរព។

២.ន សក្កច្ចំ ធម្មំ បរិយាបុណន្តិ ភិក្ខុទាំងឡាយមិនរៀនធម៌ដោយគោរព។

៣.ន សក្កច្ចំ ធម្មំ ធារេន្តិ ភិក្ខុទាំងឡាយមិនទ្រទ្រង់ធម៌ដោយគោរព។

៤.ន សក្កច្ចំ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ ភិក្ខុទាំងឡាយមិនពិចារណាអត្ថ នៃព្រះធម៌ដែលខ្លួនទ្រទ្រង់ហើយដោយគោរព។

៥.ន សក្កច្ចំ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជន្តិ ភិក្ខុទាំងឡាយដឹងអត្ថដឹងធម៌ហើយ មិនបដិបត្តិតាមសមគួរដល់ធម៌ ដោយគោរព។

## ធម៌ ៥ យ៉ាងទៀត នាំឲ្យព្រះសទ្ធម្មសាបសូន្យ គឺ ÷

១.ភិក្ខុទាំងឡាយ មិនរៀនធម៌ គឺ សុត្ត គេយ្យ វេយ្យាករណ គាថា ឧទាន ឥតិវុត្តក ជាតក អព្ភូតធម្ម វេទល្ល។

២.ភិក្ខុទាំងឡាយ មិនសម្តែងធម៌ តាមដែលខ្លួនស្តាប់បានរៀនមក ដល់បុគ្គលដទៃដោយពិស្តារ។

៣.ភិក្ខុទាំងឡាយ មិនបង្រៀនធម៌... ដោយពិស្តារ។

៤.ភិក្ខុទាំងឡាយ មិនស្វាធ្យាយធម៌... ដោយពិស្តារ។

៥.ភិក្ខុទាំងឡាយ មិនត្រិះរិះរឿយៗ មិនពិចារណារឿយៗ មិនជញ្ជឹងរឿយៗ ក្នុងចិត្ត នូវធម៌ តាមដែលខ្លួនបានស្តាប់មកបានរៀនមក។

## ធម៌ ៥ យ៉ាងទៀត នាំឲ្យព្រះសទ្ធម្មសាបសូន្យ គឺ ÷

១.ភិក្ខុទាំងឡាយ រៀនព្រះសូត្រខុស ដោយបទនិងព្យញ្ជនៈ រមែងយល់សេចក្តីបានកម្រ។

២.ភិក្ខុទាំងឡាយ ជាអ្នកប្រដៅក្រ មិនអត់ធន់ និងមិនទទួលពាក្យប្រៀនប្រដៅដោយគោរព។

៣.ភិក្ខុទាំងឡាយ ជាអ្នកចេះដឹងធម៌វិន័យច្រើន តែមិនខំបង្រៀនដល់ភិក្ខុដទៃ ធម៌វិន័យក៏បាត់បង់អស់។

៤.ភិក្ខុទាំងឡាយ ជាថេរៈ ល្មោភលាភសក្ការៈ បដិបត្តិធូរថយ ដាក់ធុរៈក្នុងវិវេក មិនមានអ្វីជាគម្រូល្អ ដល់សិស្សជំនាន់ក្រោយ។

៥.ព្រះសង្ឃបែកបាក់គ្នា... ធ្វើឲ្យជនដែលមិនទាន់ជ្រះថ្លារកជ្រះថ្លាមិនកើត ជនដែលជ្រះថ្លាមកហើយងាកចិត្តលែងជ្រះថ្លាវិញ។

## ភយន្តរាយនៃពុទ្ធសាសនា

ម៉្យាងទៀត ដើម្បីឲ្យសមស្របតាមសភាពការណ៍បច្ចុប្បន្នភយន្តរាយនៃពុទ្ធសាសនា កើតឡើងដោយហេតុ ២ គឺៈ

១.ពុទ្ធបរិស័ទ ៤ គឺ ភិក្ខុ ភិក្ខុនី (សាមណេរ)ឧបាសក ឧបាសិកា បដិបត្តិមិនល្អ ដោយខ្លួនឯង។

២.សាសនាដទៃ ឬលទ្ធិដទៃ បៀតបៀន។

## ពុទ្ធបរិស័ទ មានការខុសឆ្គងខ្លះដូចនេះគឺ ÷

១.ពុទ្ធបរិស័ទទាំង ៤ មិនបានសិក្សានូវពុទ្ធវចនៈឲ្យមានការចេះដឹងត្រឹមត្រូវ ល្មមបដិបត្តិកើត។

២.ពុទ្ធបរិស័ទទាំង ៤ បដិបត្តិមិនម៉ត់ចត់តាមពុទ្ធវចនៈទាំងនាំយកលទ្ធិផ្ទុយពីពុទ្ធសាសនា មកបដិបត្តិលាយឡំខ្លះផង។

៣.ពុទ្ធបរិស័ទទាំង ៤ ច្រើនប្រើតែសទ្ធា មិនសូវប្រើបញ្ញាផង។

៤.ភិក្ខុសង្ឃ ចង់បានលាភសក្ការៈ ច្រើនជាងចង់បានធម៌វិន័យ។

៥.ភិក្ខុសង្ឃ គិតប្រយោជន៍ផ្ទាល់ខ្លួនច្រើនជាងប្រយោជន៍រួម(ជាតិ សាសនា)។

៦.ភិក្ខុអង្គខ្លះ អាចារ្យខ្លះ នាំយកលទ្ធិផ្ទុយពីពុទ្ធសាសនាមកផ្សព្វផ្សាយទាក់លាភសក្ការៈ។

៧.ចូលចិត្តធ្វើពិធីកម្មខាងសាសនា ច្រើនជាងបដិបត្តិធម៌។

៨.មិនចេះគោរពគ្នាឲ្យបានសមរម្យ ធំតែរៀងៗខ្លួន។

៩.បាក់បែកគ្នា មិនសាមគ្គីគ្នាឲ្យបានល្អ។

១០.គណៈសង្ឃ រៀបចំនិងចាត់ចែងការគ្រប់គ្រង មិនទាន់បានគ្រប់គ្រាន់ និងមិនទាន់មានប្រសិទ្ធិភាព។

ឧទាហរណ៍ ៖ សូមពិនិត្យ និង ពិចារណាមើលកិច្ចការគ្រប់គ្រងឡើងវិញ។

អ្នកប្រព្រឹត្តខុសឆ្គងមាន តែគណៈសង្ឃមិនដឹង ឬដឹងហើយ ក៏ព្រងើយទៅ។ អ្នកប្រព្រឹត្តត្រឹមត្រូវមាន តែអ្នកបានបុណ្យសក្តិច្រើនតែអ្នក... ប៊ិនអែបអប។

ការសិក្សាអប់រំផ្តេកលើអគ្គាធិការ និងនាយកសាលា ចំរើនក៏ស្រេចតែលោក មិនចំរើនក៏ស្រេចតែលោក ចំណែកគណៈសង្ឃមិនរវល់ចង់ដឹង កម្មវិធីសិក្សាយ៉ាងម៉េច? លទ្ធផលសមតាមទិសដៅរបស់គណៈសង្ឃហើយឬនៅ? មានអ្វីហើយនៅខ្វះអ្វីទៀត? គួរបន្ថែម ឬបន្ថយយ៉ាងម៉េច? ............ ដូចជាមិនចាប់អារម្មណ៍។ ព្រះសង្ឃអ្នកចាប់អារម្មណ៍ និងជួយដោះស្រាយមានខ្លះដែរ តែច្រើនក្នុងនាមជាបុគ្គល មិនមែនជាគំនិតនិងការដោះស្រាយរបស់គណៈសង្ឃ។ ចំណែកគណៈសង្ឃដែលមិនបានចូលសាលារៀន តើថៅអធិការឲ្យការសិក្សាយ៉ាងម៉េច? អប់រំយ៉ាងម៉េច? ឮតែប្រាប់ថាឲ្យទន្ទេញធម៌ថ្វាយបង្គំព្រះ និងធម៌សូត្រមន្ត ឯទ្រឹស្តីសំខាន់ៗ របស់ព្រះពុទ្ធសាសនាមិនឮប្រាប់ មិនឮពន្យល់ផងម្លោះហើយវាច្រឡំព្រះ ព្រាហ្មណ៍ ព្រាយ លាយជាមួយគ្នា នាំឲ្យកើតទៅជាប្រេត។

ការផ្សព្វផ្សាយ ផ្សាយជាពាក្យសម្តី (ដូចជាទេសនាជាដើម) ផ្សាយជាសៀវភៅ ផ្សាយដោយទៅតាំងអង្គភាព(បង្កើតវត្តជាដើម)។ ពេលជួបគ្នា ក្រៅពីសួរសុខទុក្ខបន្តិចបន្តួចហើយមានគិតរឿងផ្សាយធម៌ឬទេ? ឃើញច្រើនតែនាំគេនិយាយលេងរឿងខ្លះក៏រោយរាយឥតប្រយោជន៍ គួរតែឆ្លៀតនិយាយធម៌អាថ៌ខ្លះ។ ទេសនា នៅតាមវត្ត ជាប្រពៃណីដ៏ល្អ ត្រូវរក្សាទុក តែយើងមានគិតឬទេ? គិតធ្វើម៉េចឲ្យគេចូលចិត្តមកស្តាប់ធម៌ឲ្យបានច្រើនគ្នា ស្តាប់ទាំងចាស់ ស្តាប់ទាំងក្មេងផង។ ទេសនានៅវត្ត គេចូលមករកយើង យើងមានគិតទេ គិតចេញទៅរកគេទៅផ្សាយដល់កន្លែងគេខ្លះ អ្ហា! មានចេញទៅដែរ ប៉ុន្តែ គេនិមន្ត កុំចាំតែគេនិមន្ត ត្រូវមានចេញទៅ តាមកម្មវិធីដែលយើងរៀបចំទេសនាតាមវិទ្យុជាតិ ក្នុងមួយឆ្នាំ មានទេសន៍ធម្មតា ប៉ុន្មានដង ទេសន៍ពិសេសប៉ុន្មានដង? គួរតែមានគម្រោងការច្បាស់លាស់ថា ឆ្នាំនេះត្រូវបញ្ចេញគោលធម៌ប៉ុណ្ណោះមាតិកា ឲ្យប្រជាជនស្តាប់ មិនគួរបណ្តោយតាមមានតាមបានទេ ទេសនាពិសេស គួរចាត់អង្គណាទៅ អ្នកប្រាជ្ញព្រាវ កុំយកទៅប្រើការធ្លាប់មានមកហើយ យកគំនិតផ្ទាល់ខ្លួនឆ្លើយដាក់គម្ពីរ ឆ្លើយដាក់ព្រះពុទ្ធ គណៈសង្ឃបានស្តាប់ឬទេ? គិតយ៉ាងម៉េចដែរ? ទេសន៍តាមវិទ្យុជាតិ កុំបណ្តោយពេក។ ម្យ៉ាងទៀត ឯកជន ឬក្រុមឯកជន គេមានមធ្យោបាយ ផ្សាយធម៌តាមវិទ្យុបាន គួរឲ្យអនុមោទនា។ គណៈសង្ឃទាំងមូលគួររកមធ្យោបាយផ្សាយធម៌ បន្ថែមពីវិទ្យុជាតិ ទៀតបានឬទេ? ឬក៏ដេកលក់តទៅទៀត។

ការបោះពុម្ពសៀវភៅ ក្រសួងធម្មការនិងពុទ្ធសាសនបណ្ឌិត្យបានជួយមួយចំនួនធំ ប៉ុន្តែនៅខ្វះទៀតច្រើនណាស់។ គម្ពីរអដ្ឋកថា ដីកាក្តី សៀវភៅសម្រាប់សិក្សាស្វែងយល់ធម៌អាថ៌ ក្នុងពុទ្ធសាសនាក្តី ត្រូវតែបង្កើតឲ្យមានច្រើនថែមទៀត។ ចំឡែកការបកប្រែជាភាសាបរទេស មកដល់ពេលនេះហើយយើងស្ទើរតែគ្មានសោះ។ តើគណៈសង្ឃគិតគូរយ៉ាងម៉េចដែរ អ្នកណាទទួលខុសត្រូវរឿងពុទ្ធសាសនាច្រើនជាងគេ មិនមែន អស់លោកជាគ្រហស្ថនៅក្រសួងធម្មការ និងពុទ្ធសាសនបណ្ឌិត្យទេ លោកគ្រាន់តែជួយ យើងអរគុណសន្ទឹកណាស់ទៅហើយ អ្នកទទួលខុសត្រូវច្រើនជាងគេ គឺ គណៈសង្ឃ។

ផ្សព្វផ្សាយ ដោយទៅតាំងជាអង្គភាព ឬបង្កើតវត្ត។ នៅកន្លែងណាក្រីក្រ កន្លែងឆ្ងាយដាច់ស្រយាល កន្លែងព្រំដែនត្រូវតែរួបរួមកម្លាំងគ្នាទៅជួយកសាង ទៅនៅចាំវត្តដើម្បីបានជាទីពឹងពំនាក់នៃប្រជាជន យ៉ាងហោចណាស់ក៏ដាក់វេនគ្នាទៅនៅចាំវត្តដែរ មិនមែនរត់មកកុំតែទីប្រជុំជនទេ។ នៅបរទេសក៏ត្រូវតែមានគម្រោងការផ្សព្វផ្សាយពុទ្ធសាសនាទៅដែរ ប៉ុន្តែ សព្វថ្ងៃប្រទេសយើងក្រីក្រ តែជាភព្វល្អម្យ៉ាង ដែលខ្មែរយើងភៀសខ្លួនទៅបាននាំគ្នាកសាងវត្តខ្មែរជាច្រើន តើរឿងនេះ គណៈសង្ឃគិតយ៉ាងម៉េចដែរ មានគម្រោងអ្វី ដើម្បីជួយវត្តខ្មែរនោះឲ្យបានជាទីជ្រះថ្លារបស់ខ្មែរផង របស់ជនបរទេសផង ហើយក៏ជាកិត្តិយសដល់ជាតិខ្មែរយើងយូរអង្វែងទៅផង។ ឬទុកគ្រាន់តែទៅ...............

ក្រៅពីកិច្ចការខាងលើនេះ សព្វថ្ងៃនៅប្រទេសយើងអបាយមុខកំពុងតែចំរើនរីករាលដាល តើគណៈសង្ឃគិតយ៉ាងម៉េច? មានគម្រោងជួយកំចាត់ឬ បន្ថយដែរឬទេ? មានគម្រោងជួយការពារ ឬ ព្យាបាលអប់រំអ្នករងគ្រោះនោះដែរឬទេ? ប្រទេសយើងជាប្រទេសកសិកម្ម រួចពី ប៉ុល ពត មកជាង ២០ ឆ្នាំហើយ បន្លែនៅតែទិញគេស៊ី ។ល។ តើគណៈសង្ឃគិតយ៉ាងម៉េច? ព្រះសង្ឃសាសនាឯទៀតក្តី ព្រះសង្ឃពុទ្ធសាសនា មហាយានក្តី ព្រះសង្ឃពុទ្ធសាសនាថេរវាទក្តី ក្រៅពីព្រះសង្ឃខ្មែរ សព្វថ្ងៃគេធ្វើអ្វីខ្លះ បានសិក្សាតាមដានខ្លះដែរទេ មានអ្វីល្អគួររៀនសូត្រតាមដែរឬទេ? បើមាននរណា គេពោលបង្កាច់ប្រមាថមើលងាយឬបៀតបៀនពុទ្ធសាសនាក្នុងប្រទេសក្តី ក្នុងអន្តរជាតិក្តី តើមានអ្នកតាមដឹងដែរឬទេ? អ្នកណាជាអ្នកឆ្លើយ បំភ្លឺ ការពារឬ ដោះស្រាយរឿងអស់នេះ ឬចេះតែស្ងៀមទៅ.... សូមគណៈសង្ឃ ពិចារណាតាមការគួរចុះ។

# ភយន្តរាយកើតពីសាសនាដទៃ

## ពួកអន្យតិរ្ថិយ៍
## រឿង នាងចិញ្ចាមាណវិកា



ក្នុងបឋមពោធិកាល លាភសក្ការៈដ៏ច្រើន បានកើតឡើងដល់ព្រះសម្មាសម្ពុទ្ធ និងព្រះសង្ឃសាវក។ ឯលាភសក្ការៈនៃពួកអន្យតិរ្ថិយ៍ចុះអនថយទៅ ដូចអំពិលអំពែកត្រូវថ្ងៃ។ ពួកអន្យតិរ្ថិយ៍ប្រជុំគិតគ្នាថា ពួកយើងសាបសូន្យលាភសក្ការៈដោយសាតែសមណគោតម ដូចនេះយើងត្រូវរកឧបាយលើកទោសដាក់សមណគោតម។ អន្យតិរ្ថិយ៍ ឆ្លាតម្នាក់ពោលឡើងថា បរិព្វាជិការបស់យើងម្នាក់ឈ្មោះនាងចិញ្ចាមាណវិកា រូបល្អសោភាស្រស់ប្រិមប្រិយណាស់ យើងត្រូវពឹងនាងឲ្យជួយដោះស្រាយរឿងនេះ។ ទីប្រជុំ បានយល់ស្របជាឯកច្ឆន្ទ។

ពេលនាង ចិញ្ចា ចូលទៅកាន់វត្តថ្វាយបង្គំពួកអន្យតិរ្ថិយ៍ៗនៅស្ងៀម អត់និយាយរកអស់វារៈពីរបីដង។ នាងចិញ្ចាសួរថាតើនាងខ្ញុំមានខុសឆ្គង់រឿងអ្វី? បានជាព្រះករុណា មិននិយាយរក។ ពួកអន្យតិរ្ថិយ៍ និយាយថា នាងមិនដឹងទេឬ? ពួកយើង សព្វថ្ងៃ កំពុងតែវិនាសហិនហោច ដោយសាតែសមណគោតម រឿងនេះ ត្រូវតែនាងជួយដោះស្រាយ គិតធ្វើយ៉ាងម៉េច ឲ្យសមណគោតម ខូចកេរ្តិ៍ឈ្មោះ....។ អ្ហោ អីចឹងទេឬ ...? មិនអីទេរឿងណឹងចាំខ្ញុំព្រះករុណាគិតដោះស្រាយ នាងចិញ្ចា ឆ្លើយ។

ពេលល្ងាច មហាជនចេញពីស្តាប់ធម៌នៅវត្តជេតពន នាងចិញ្ចា ស្លៀកពាក់ស្អាតកាន់ផ្កាភ្ញីរដើរទៅ...មហាជន សួរថានាងឯងទៅណា ពេលថ្មើរណឹង។ ប្រយោជន៍អីរបស់ពួកអ្នកឯងដោយរឿងទៅណាមកណារបស់ខ្ញុំ នាងចិញ្ចា ឆ្លើយ ហើយក៏ដើរបង្ហួសទៅស្នាក់នៅវត្តអន្យតិរ្ថិយ៍។

ពេលព្រឹក មហាជន ដើរទៅកាន់វត្ត ដើម្បីថ្វាយបង្គំគាល់ព្រះពុទ្ធ នាងចិញ្ចា ក៏ដើរត្រឡប់មកដែរ មហាជន សួរថានាងឯង នៅឯណា? មកពីណា? ប្រយោជន៍អីរបស់ពួកអ្នកឯងដោយការសួររកកន្លែងនៅរបស់ខ្ញុំ នាងចិញ្ចា ឆ្លើយហើយក៏ដើរហួសទៅកាន់វត្តអន្យតិរ្ថិយ៍។

មួយខែពីរខែកន្លងមក មហាជនសួរថា នាងឯងនៅឯណា? នាងចិញ្ចា ឆ្លើយថា ខ្ញុំនៅវត្តជេតជន ជាមួយសមណគោតមរាល់តែយប់...។ ប្រជាជន ចាប់មានសេចក្ដីសង្ស័យ។ បីបួនខែកន្លងមក នាងចិញ្ចា យកសំពត់រុំព័ទ្ធពោះខ្លួនធំបន្តិច។ ប្រាំបួនខែមកដល់ នាងចិញ្ចាយកដុំឈើរុំពាន់ព័ទ្ធពោះខ្លួនប៉ោងធំសម្បើម ដើរចូលទៅកាន់វត្ត ហើយនិយាយឡើងក្នុងពេលដែលព្រះពុទ្ធអង្គកំពុងតែសម្ដែងធម៌ទេសនាថា សមណគោតម ពូកែតែសម្ដែងធម៌ប្រាប់គេ ត្រង់ខ្លួនឯងអត់រវល់ ខ្ញុំគ្រប់ខែហើយមិនឃើញមានត្រៀមរបស់អីសោះ បើមិនធ្វើខ្លួនឯង ក៏គួរតែពឹងនាងវិសាខា ឬអនាថបិណ្ឌិកឲ្យជួយដោះស្រាយដែរ... រឿងសប្បាយចេះ តែរឿងចាត់ការមិនចេះ។ ព្រះពុទ្ធ ត្រាស់ថា រឿងដែលនាងនិយាយ ពិតឬមិនពិត គ្មាននរណាដឹងទេ មានតែតថាគត និងនាង ទើបដឹងរឿងពិតនេះ។

ពេលនោះ ក្ដៅក្រហាយដល់សក្កទេវរាជ លោកចុះមកជាមួយនឹងទេវបុត្ត ៤ អង្គ និមិត្តជាកណ្ដុរកាត់ខ្សែចំណងពោះដុំឈើធ្លាក់ចុះ ត្រូវជើងនាងចិញ្ចាបែកចេញឈាម។ មហាជនដឹងសេចក្ដីពិតថា នាងចិញ្ចា ជាមនុស្សកាឡកណ្ណី ក៏វាយតប់អូសទាញចេញពីវត្តទៅមិនឆ្ងាយប៉ុន្មាន ព្រះធរណីក៏ស្រូបធ្លាក់ចុះទៅនរកអវចី។ ពួកអន្យតិរ្ថិយ៍ ក៏រីតតែសាបសូន្យ លាភសក្ការៈ ឯពួកសមណគោតម ក៏រីងរឹតតែរុងរឿងឡើង៕

## រឿង នាងសុន្ទរី

នាងសុន្ទរី ជាបរិព្វាជិកា របស់អន្យតិរ្ថិយ៍។ នាងព្រមទទួលយកអាសា ដូចនាងចិញ្ចា ដើម្បីធ្វើបង្ខូចកិត្តិយសព្រះពុទ្ធសាសនា។ សាច់រឿងរបស់នាងសុន្ទរី ខាងដើមដូចគ្នានឹងរឿងនៃនាងចិញ្ចាទាំងអស់ប្លែកគ្នាត្រង់ចំណុចខាងចុងប៉ុណ្ណោះ។ ចំណុចចុងក្រោយ ពេលដែលមហាជន កំពុងកើតសេចក្ដីសង្ស័យដោយឮនាងសុន្ទរីនិយាយថា ខ្លួនទៅដេកជាមួយព្រះពុទ្ធ ក្នុងវត្តជេតពន ពួកអន្យតិរ្ថិយ៍ ក៏ជួលពួកអ្នកលេងឲ្យសម្លាប់នាងសុន្ទរីភ្លាម ហើយកប់លាក់ទុកក្នុងវត្តជេតពននោះ។ ពួកអន្យតិរ្ថិយ៍ នាំគ្នាស្រែកឆោឡោថា បាត់នាងសុន្ទរី ហើយនាំគ្នាដើររក ស្រាប់តែបានឃើញសពនាងសុន្ទរីកប់លាក់ក្នុងវត្ត។ គេនាំគ្នាស្រែកអាក្រោសឃោសនាថា សមណគោតម មិនមែនជាសមណៈទេដេករួមជាមួយនាងសុន្ទរី ហើយ សម្លាប់គេចោលបំបាត់ភ័ស្ដុតាងទៀត....។ ដំណឹងនេះឮខ្ទរខ្ទារពេញផ្ទៃប្រទេសទាំងមូល ភិក្ខុសង្ឃចេញទៅបិណ្ឌបាតឮតែពាក្យជេរប្រទេច ដោយប្រការផ្សេងៗ កាលទ្រង់ព្រះសណ្ដាប់ដូចនេះ ព្រះរាជាគួរតែសប្បាយព្រះទ័យ តែបែរជាក្ដៅក្រហាយ រហូត

ដល់ធ្លាក់ព្រះលោហិតដួលស្រុបចំពោះមុខកងទ័ព សោយទីវង្គតក្នុងទីនោះឯង។ ក្នុងខណៈជាមួយគ្នានោះ ព្រះបាទបុរាណវរមា យាត្រាទ័ពមកដល់ កងទ័ពព្រះបាទសាសង្កា ភិតភ័យតក់ស្លុត រត់បែកខ្ចាត់ខ្ចាយអស់។

## ព្រះបាទបុស្សមិត្ត

ព្រាហ្មណ៍ម្នាក់ឈ្មោះ សុង្គៈ បានធ្វើជាអាមាត្យរបស់ព្រះបាទព្រឹហត្ថិ មានចិត្តក្បត់លបធ្វើគត់ព្រះបាទព្រឹហត្ថិ ហើយប្រាប្ដាភិសេក លើកខ្លួនឯងធ្វើជាស្ដេច ព្រះនាមបុស្សមិត្ត តាំងវង្សត្រកូល សុង្គៈ ឡើង។

ពួកព្រាហ្មណ៍ មិនសប្បាយចិត្តនឹងការហាមសម្លាប់សត្វបូជាយញ្ញ មិនសប្បាយចិត្តនឹងព្រះបាទអសោកមហារាជ ទំនុកបម្រុងព្រះពុទ្ធសាសនាឲ្យចំរើនរុងរឿងទេ លុះព្រះរាជវង្សមោរ្យៈ រលត់សូន្យ ដូចនេះ ព្រាហ្មណ៍ បានឱកាសពង្រីកឥទ្ធិពលសាសនាព្រាហ្មណ៍ យ៉ាងសម្បើម។ ព្រះបាទ បុស្សមិត្ត តាំងខ្លួនជាបដិបក្ខ ចំពោះពុទ្ធសាសនា បានរំលាយវត្តអារាម និង កាប់សម្លាប់ភិក្ខុសង្ឃអស់ជាច្រើន ព្រមទាំងបានឲ្យជារង្វាន់ដល់អ្នកដែលបានសម្លាប់ភិក្ខុសង្ឃទៀតផង។

ព្រះសង្ឃភិតភ័យតក់ស្លុតរត់ចេញពីដែនមគធៈទៅកាន់ទិសផ្សេងៗ ជាច្រើន។ ពេលនោះ ព្រះពុទ្ធសាសនា រោយរៀវចុះ យ៉ាងខ្លាំង។ ឯសាសនាព្រាហ្មណ៍ រុងរឿងឡើងវិញ៕

## សង្ករាចារ្យ

សង្ករាចារ្យ អ្នកប្រាជ្ញរបស់ពួកព្រាហ្មណ៍ បានសិក្សាពុទ្ធសាសនាយ៉ាងជ្រៅជ្រះ(ឯកសារខ្លះថា បានចូលមកបួសផង) បានចម្លងរបៀប[៦] និងគោលធម៌ពុទ្ធសាសនាមួយចំនួនយកទៅរៀបចំចាត់ចែង និងសរសេរដាក់ក្នុងគម្ពីររបស់ខ្លួន (វេទាន្តៈ និង ឧបនិស័ទ)។ បន្ថែមពីលើនេះទៀតគាត់តែងរឿងប្រឌិតថា ព្រះពុទ្ធសមណគោតម មិនគឺអ្វីដទៃទេ គ្រាន់តែជាការបែងភាគទី ៩ របស់ព្រះនរាយណ៍ ហៅថា ពុទ្ធាវតារ តែប៉ុណ្ណោះ។ ដូចនេះ ព្រះពុទ្ធតូចជាងព្រាហ្មណ៍ ការគោរពព្រះពុទ្ធក៏មិនប្រសើរស្មើគោរពព្រាហ្មណ៍ទេ។ វិធី

---

[៦] *ព្រាហ្មណ៍ពីដើម មិនមានវត្តអារាមធំដុំទេ មិនមានព្រះរតនត្រ័យទេ។*

នេះធ្វើឲ្យពួកប្រជាជន ដែលឆោតល្ងង់មួយចំនួន រត់ចេញពីព្រះពុទ្ធសាសនាទៅចូលព្រាហ្មណ៍វិញ។

តមកទៀត ពួកព្រាហ្មណ៍ចូលមកបួសបន្លំក្នុងពុទ្ធសាសនាបាននាំយក លទ្ធិតន្ត្រៈរបស់ព្រាហ្មណ៍ ដែលច្របូកច្របល់ដោយកាមគុណ និងមន្តអាគមគាថា មកបដិបត្តិលាយឡំភិក្ខុសង្ឃដែលលាមក ល្មោភលាភសក្ការៈ និងសេចក្តីសប្បាយក៏រីករាយបដិបត្តិលាយឡំទៅជាមួយគ្នា នេះជាហេតុធ្វើឲ្យពុទ្ធសាសនា រឹតតែរោយរៀវចុះខ្លាំងទៀត៕

## សាសនា គ្រិស្ត

### ប្រទេសសិរីលង្កា

ជនជាតិ ពរទុយគ្កេស ចូលទៅរកស៊ីលក់ដូរ នៅប្រទេសសិរីលង្កា ឆ្លៀតឱកាសដែលប្រទេសសិរីលង្កា កំពុងចុះទន់ខ្សោយក៏ដណ្តើមយកទឹកដីភាគខ្លះ ហើយបង្គាប់ប្រជាជន ត្រង់កន្លែងដែលខ្លួនគ្រប់គ្រង់នោះ ឲ្យផ្លាស់ប្តូរសាសនា គឺឲ្យផ្លាស់ពីកាន់ពុទ្ធសាសនា មកកាន់សាសនាគ្រិស្តវិញ និកាយកាតូលិក។ អំពើនេះ ធ្វើឲ្យប្រជាជនក្តៅក្រហាយយ៉ាងខ្លាំង ហើយពុទ្ធសាសនា ក៏ចុះអន់ថយយ៉ាងច្រើនដែរ។

តមក ជនជាតិ ហុលឡង់ ចូលទៅរកស៊ីលក់ដូរនៅប្រទេសសិរីលង្កា ដូចជនជាតិ ពរទុយគ្កេស ដែរ។ ជនជាតិសិរីលង្កាទទួលជនជាតិហុលឡង់ ក្នុងគោលគំនិតដើម្បីរួមគ្នាដេញជនជាតិ ពរទុយគ្កេស ឲ្យចេញទៅវិញ។ រួមគ្នាដេញ ពរទុយគ្កេស ចេញបានមែន ប៉ុន្តែ ពួកហុលឡង់មិនព្រមចេញ ដណ្តើមយកទឹកដីកន្លែងនោះ ជំនួសពរទុយគ្កេស បង្គាប់ប្រជាជនឲ្យកាន់សាសនាគ្រិស្ត និកាយប្រូតិសស្តង់ ហើយហាមឃាត់ មិនឲ្យកាន់ពុទ្ធសាសនា។

តមកទៀត ជនជាតិអង់គ្លេសចូលទៅវាតទីគ្រប់គ្រងប្រទេសសិរីលង្កា គាបសង្កត់រដ្ឋាភិបាល មិនឲ្យទាក់ទងនឹងពុទ្ធសាសនា បើកឱកាសឲ្យអ្នកបួសគ្រិស្តសាសនា វាយប្រហារពុទ្ធសាសនា យ៉ាងចេញមុខ។ អំពើបៀតបៀននេះ នាំឲ្យពុទ្ធសាសនាអាប់អោនចុះអន់ថយ អស់រយៈពេល ៣០០ ឆ្នាំ ៕

# ប្រទេសវៀតណាម

ពីដើមមក ប្រជាជនវៀតណាម កាន់សាសនាខុងជឺ និងពុទ្ធសាសនា។ ក្រោយមក ពួកអាណានិគមនិយមជាច្រើនពរទុយគ្លេស ហុលឡង់ អេស្ប៉ាញ គង់គ្លេស បារាំង បានចូលទៅកាន់ប្រទេសវៀតណាម ហូរហែបន្តបន្ទាប់គ្នា ដោយបាននាំយកសាសនាគ្រិស្ត ទៅជាមួយផង។ ប្រជាជនវៀតណាម មិនចូលចិត្តសាសនាគ្រិស្តទេ បានព្យាយាមតស៊ូកំចាត់សាសនានេះ គ្រប់រូបបែបទាំងអស់ សូម្បីតែរដ្ឋាភិបាលក៏មិនចូលចិត្តសាសនាគ្រិស្តដែរ បានបោះត្រាលើថ្ពាល់ខាងឆ្វេងសំគាល់ទីកន្លែងដែលពួកអស់នោះស្នាកនៅ។ ពេលខ្លះ មានការបៀតបៀនកាប់សម្លាប់គ្នា ស្លាប់រាប់ម៉ឺនសែនផង។

ពេលដែលបារាំង ចូលត្រួតត្រាប្រទេសវៀតណាម បានសម្រេចហើយ គេប្រើវិធីអូសទាញ និងគាបសង្កត់ផ្សេងៗ ចែកអំណោយ សង់សាលារៀន បន្ទីរពេទ្យ ។ល។ អ្នកណាចង់បានបុណ្យស័ក្តិធំ ត្រូវចូលជាតិបារាំង ដើម្បីចូលជាតិបារាំងបាន ត្រូវកាន់សាសនាគ្រិស្ត ។ល។ សូម្បីគេធ្វើដូចនេះក៏ដោយ សាសនាគ្រិស្តក៏មិនទាន់រីកចំរើនឡើងខ្ពស់ណាស់ដែរ។ ប៉ុន្តែ ដល់សម័យ ង៉ោ-ឌិនយៀម ឡើងធ្វើប្រធានាធិបតីទី ១ របស់ប្រទេសវៀតណាម ត្រកូលង៉ោ ដែលសុទ្ធតែកាន់សាសនាកាតូលិកឡើងត្រួតត្រា ប្រទេសវៀតណាម គឺ៖

| | |
|---|---|
| **ង៉ោ-ឌិនយៀម** | ប្រធានាធិបតី |
| **ង៉ោ-ឌិនធឹក** | សម្តេចសង្ឃកាតូលិក |
| **ង៉ោ-ឌិនញ៉ូវ** | កាន់កងទ័ពពិសេស ចាត់ការជំនួសប្រធានាធិបតី |
| **ម៉ាដាម ញ៉ូវ** | ជាស្ត្រីលេខ ១ របស់វៀតណាម |
| **ង៉ោ ឌិនខាន** | ចៅហ្វាយក្រុងវេ |
| **ង៉ោ ឌិនលឿង** | ទូតប្រចាំប្រទេសអង់គ្លេស |

ពេលនោះហើយ ដែលគេចាប់បន្ថោកពុទ្ធសាសនា។ ប្រជាជនវៀតណាមខាងជើង ៤ សែននាក់ ភៀសខ្លួនមកភាគខាងត្បូង ជនជាតិវៀតណាមណា កាន់សាសនាកាតូលិក គេយកចិត្តទុកដាក់ជួយច្រើន ជនជាតិវៀតណាមណា កាន់ពុទ្ធសាសនា គេមិនសូវយកចិត្តទុកដាក់ទេ។ ម៉ាដាមញ៉ូវ និយាយថា ព្រះពុទ្ធសាសនា អន់ណាស់អាច់ផ្លាស់មកកាន់សាសនាកាតូលិកក៏ល្អជាង។

ថ្ងៃ ៥ ឧសភា ១៩៦៣ មានការចាត់ធ្វើបុណ្យឆ្លង ២៥ ឆ្នាំ នៃសម្តេចសង្ឃ ង៉ោ-ឌិនធឹក នៅក្រុងដាឡាត់ មានលើកទង់ កាតូលិក ក្រុងវ៉ាទិកង់ ដោយអត់លើកទង់ជាតិវៀតណា

មផងទេ។ ដល់ថ្ងៃ ៨ ឧសភា ១៩៦៣ ជាថ្ងៃវិសាខាបូជា ពុទ្ធបរិស័ទ លើកទង់ពុទ្ធសាសនាឆព្វណ្ណរង្សី ប៉ូលិសទាញដាក់ចុះ ហើយហែកចោល។ រឿងនេះ ធ្វើពុទ្ធបរិស័ទ ក្តៅក្រហាយយ៉ាងខ្លាំង។

ព្រះសង្ឃវៀតណាម ១ អង្គ ឲ្យសម្ភាសន៍សារពត៌មានឡៃហ្វ៍ ថាបើនរណាចង់បាន ចង់មាន ឬចង់បានបុណ្យសក្តិធំ ត្រូវចូលកាន់សាសនាកាតូលិក។ ជនវៀតណាម ១ នាក់ទៀតនិយាយថា ពេលដែលបារាំងគ្រប់គ្រង វាមិនអាចយក ចក្រពត្តិកាតូលិក មកគង់លើបល្លង្គវៀតណាមបានទេ ប៉ុន្តែ ឥឡូវ អាមេរិកបានយក ចក្រពត្តិកាតូលិក មកឲ្យពួកយើងបាន ១ អង្គហើយ។ បើត្រកូលង៉ោ សោយរាជ្យបានយូរ ប្រហែលជា ពុទ្ធសាសនាងាប់អស់៕

## សាសនា ឥស្លាម

ជាច្រើនសតវត្សរ៍មកហើយ កងទ័ពឥស្លាមបានចូលទៅរុករានបៀតបៀន កំទេចកំទី ពុទ្ធសាសនា នៅប្រទេសឥណ្ឌា លុះដល់ ព.ស.១៧០០ កងទ័ពឥស្លាម បានកាប់សម្លាប់ភិក្ខុសង្ឃដុតកំទេច គម្ពីរ ដីកា សេនាសនៈ និង មហាវិទ្យាល័យ ដ៏ធំបំផុត ឈ្មោះនាលន្ទាឆេះអស់គ្មានសល់។ ពុទ្ធសាសនាក៏សាបសូន្យ ពីប្រទេសឥណ្ឌាអស់រយៈពេលប្រហែល ៨០០ឆ្នាំ គ្មាននរណាដឹងឮទេ ទើបនឹងចាប់មានឡើងវិញពី ព.ស.២៤៣៦ ដោយអនាគារិកៈធម្មបាលៈ ជាតិសិរីលង្កា។



នៅប្រទេសឥណ្ឌូនេស៊ី ពីដើមមក ប្រជាជនកាន់ពុទ្ធសាសនាដែរ តែក្រោយមក សាសនាឥស្លាមចូលទៅ ក៏វាយកំទេចពុទ្ធសាសនាអស់គ្មានសល់។ សព្វថ្ងៃ នៅសល់ប្រាសាទថ្មជាពុទ្ធស្ថាន ហៅថា ប៉ុររ៉ូពុតឌោ ឬបរមពុទ្ធោ ជាភ័ស្តុតាងស្រាប់។



នៅប្រទេស អាហ្វ្រានិស្ថាន ពីដើមមក ប្រជាជនកាន់ពុទ្ធសាសនាដែរ តែក្រោយមក សាសនាឥស្លាមចូលទៅ ក៏វាយកំទេចពុទ្ធសាសនាអស់ នៅសល់តែព្រះពុទ្ធរូបថ្ម ១ អង្គធំដែលពួកវាទើបនឹងបាញ់កំទេចថ្មីៗ ក្នុងគ.ស.២០០១ នេះឯង៕

## លទ្ធិកុម្មុយនិស្ត

លទ្ធិកុម្មុយនិស្ត ជាខ្មាំងសត្រូវធំបំផុតនៃគ្រប់សាសនាទាំងអស់ មិនមែនចំពោះពុទ្ធសាសនាមួយទេ។ លទ្ធិនេះមាននៅទីណា ទីនោះមិនមានសាសនាទេ ឬគេទុកបន្តិចគ្រាន់តែដើម្បីបោកបញ្ឆោតតែប៉ុណ្ណោះ។ រឿងកុហកបោកបញ្ឆោតនេះ ពូកែលេខ ១ ប៉ុន្តែ រឿងពិតយើងឃើញផ្ទាល់ខ្លួនយើង នៅស្រុកខ្មែរ គ្មាននរណាដឹងថា អាចអត់សាសនាទៅកើតទេ ប៉ុន្តែ ពួកកុម្មុយនិស្ត គេអាចធ្វើតែមួយភ្លែតឲ្យអតស់សាសនាបានទៅភ្លាម។ ដូចនេះ កុំចាញ់បោកកុម្មុយនិស្តទៀត៕

## ការបញ្ឆេះភ្លើងសង្គ្រាម

ការនិយាយពីភយន្តរាយ កើតពីសាសនាដទៃ ឬលទ្ធិដទៃយ៉ាងនេះ មុខជាមានគេចោទឡើងថា៖ គេកំពុងតែមានមិត្តភាព កំពុងតែរួមរស់ក្នុងសន្តិភាព... ឯងតាំងចាប់បញ្ឆេះភ្លើងសង្គ្រាមទៀតហើយ។ ការចោទយ៉ាងនេះ មិនមែនជារឿងថ្មីទេ ជាមេរៀនចាស់ដដែលៗ គេថា ពួកយើងយល់ច្រឡំហើយ គេមិនដូចនោះទេ ប៉ុន្តែ នេះក៏គ្រាន់តែដើម្បីញុះញង់ឲ្យយើងបាក់បែកគ្នា និងដើម្បីឲ្យយើងភ្លេចខ្លួនតទៅទៀតតែប៉ុណ្ណោះ។

យើងពុទ្ធសាសនា មិនដែលធ្វើសង្គ្រាមនឹងនរណាទេ ហើយក៏មិនប្រាថ្នាធ្វើសង្គ្រាមទៅអនាគតដែរ។ យើងពុទ្ធសាសនា មានចិត្តល្អ តែងតែបើកឲ្យមានសេរីភាព ប៉ុន្តែពេលខ្លះ ភ្លេចខ្លួនរហូតដល់មានគ្រោះថ្នាក់ក៏មានដែរ។ ការលើករឿងនេះមកនិយាយ មិនមែនដើម្បីបញ្ឆេះសង្គ្រាមទេ ដើម្បីចែកការចេះដឹងគ្នា ដ្បិតបុគ្គលមិនចេះដឹងប្រវត្តិសាស្ត្រពុទ្ធសាសនាច្រើនណាស់ និងដើម្បីរំលឹកគ្នាកុំឲ្យប្រមាទ ព្រោះប្រមាទជាផ្លូវនៃសេចក្តីស្លាប់៕

## សាសនាណាក៏ល្អដែរ

បុគ្គលខ្លះគេចូលចិត្តនិយាយថា សាសនាណាក៏ល្អដែរ។ តើគេមានបំណងយ៉ាងណា? គេចង់ឲ្យយើងកាន់សាសនាផ្ទេចផ្អែក ឬចង់ឲ្យប្រាប់ថាសាសនាល្អដូចៗគ្នាស្មើគ្នាទេ? យើងជឿថា សាសនាណាក៏ល្អដែរ បានជាមានមនុស្សគេជឿគេកាន់ ប៉ុន្តែ ល្អមិនដូចគ្នាទេ មិនស្មើគ្នាទេ។ សាសនាខ្លះល្អតិច សាសនាខ្លះល្អច្រើន ខ្លះល្អត្រឹមកម្រិតមនុស្ស ឬទេវតា ខ្លះល្អរហូតដល់និព្វាន។ ឯវិធីដែលបានល្អនោះមក ក៏មិនដូចគ្នា ខ្លះបានមកដោយបន់ស្រន់ ឬសុំគេ ខ្លះបានមកដោយធ្វើខ្លួនឯង។ ឯវិធីដែលធ្វើខ្លួនឯងនោះ ក៏មិនដូចគ្នាទៀត ខ្លះចង់ជ្រះបាប ត្រូវចុះងូតទឹកទន្លេ ខ្លះចង់ជ្រះបាប ត្រូវឈប់ធ្វើអាក្រក់ ត្រូវជម្រះកិលេស។ យើងគួរគិតពិចារណាមើលដែរ បើល្អដូចគ្នា ម៉េចក៏ចាំបង្គាប់ឲ្យគេបោះបង់សាសនាគេចោល ហើយអួសទាញគេឲ្យចូលមកកាន់សាសនាខ្លួន។ ល្អដូចគ្នា លុះណាតែមានពាក្យប្រៀនប្រដៅ(រូបមន្ត)ដូចគ្នា ចុះបើពាក្យប្រៀនប្រដៅវាផ្ទុយគ្នាទៅហើយ តើឲ្យផលដូចគ្នាយ៉ាងម៉េច។ ដូចនេះពាក្យថា សាសនាណាក៏ល្អដែរ មិនមែនជាពាក្យរបស់អ្នកប្រាជ្ញទេ មិនមែនជាពាក្យរបស់អ្នកមានគំនិតជ្រៅទេ ប្រហែលជាពាក្យរបស់មនុស្ស... ឬមនុស្សបោកឲ្យចូលសាសនាគេតែប៉ុណ្ណោះ៕

## កាន់ពុទ្ធសាសនា មិនឃើញបានសុខ

អ្នកខ្លះ និយាយថា កាន់ពុទ្ធសាសនា មកយូរហើយមិនឃើញបានសុខសោះ បានតែទុក្ខ ដោយឡែកក្នុងរបប ប៉ុល ពត។ សូមជម្រាបថា ក្នុងរបប ប៉ុល ពត មិនចំពោះតែកាន់ពុទ្ធសាសនាទេ កាន់សាសនាអីក៏ទុក្ខទាំងអស់ ព្រោះរបប ប៉ុល ពត (កុម្មុយនិស្ត) ប្រឆាំងគ្រប់សាសនាទាំងអស់។ សូមឲ្យយើងគិតពិចារណាមើល រឿងសុខទុក្ខ តើនរណាសាងឲ្យនរណា? ប្រជាជនជាអ្នកសាងសេចក្តីសុខផ្ទាល់ខ្លួន អ្នកដឹកនាំរដ្ឋ ជាអ្នករៀបចំច្បាប់ ធ្វើគម្រោងការ ហើយដឹកនាំ ជួយសម្រួលឲ្យប្រជាជនសាងសេចក្តីសុខដោយខ្លួនឯង។ ចំណែក សាសនា មិនមែនមានតួនាទីដឹកនាំផ្ទាល់ទេ ទួនាទីរបស់សាសនាគឺ ជួយប្រាប់ជាផ្លូវគំនិតឲ្យគេឈប់ធ្វើសេចក្តីអាក្រក់ ឲ្យគេខំធ្វើល្អ និងឲ្យគេជម្រះចិត្តរបស់ខ្លួនឲ្យស្អាត។ បើគេមិនព្រមធ្វើតាម តើឲ្យសាសនាធ្វើយ៉ាងម៉េច? ក្រៅពីសេចក្តីសុខកើតពីទ្រព្យសម្បត្តិ ហើយ ពុទ្ធសាសនា មានបង្រៀនឲ្យគេរំលត់ទុក្ខ សាងសេចក្តីសុខដោយវិធីផ្សេងទៀតផ្សំ

ផងដែរ (សមថៈ វិបស្សនា) តែគេមិនសូវពេញចិត្តធ្វើតាម។ យ៉ាងនេះ គួរបន្ទោស ពុទ្ធសាសនាដែរឬ?

អ្នកខ្លះ និយាយថា មកពីកាន់ពុទ្ធសាសនា បានជាទុក្ខលំបាក បើកាន់សាសនាឯទៀត មិនលំបាកអីចឹងទេ។ ពាក្យនេះ មិនពិតសោះ សូមសង្កេតមើល ឥណ្ឌាកាន់សាសនាហិណ្ឌូ ឥណ្ឌូនេស៊ីកាន់សាសនាឥស្លាម ហ្វីលីពីនកាន់សាសនាគ្រិស្ត ម៉េចក៏ទុក្ខលំបាកដែរ។ ថៃកាន់ពុទ្ធសាសនា ដូចខ្មែរយើងដែរ ម៉េចក៏គេសុខសប្បាយ។ អ្នកខ្លះទៀត និយាយថា បើចូលកាន់សាសនាដទៃ គេជួយច្រើនណាស់ គួរតែផ្លាស់សាសនាម្តង៕

## ផ្លាស់សាសនា វាយ៉ាងម៉េច ?

មនុស្សមានសេរីភាពគ្រប់គ្រាន់ក្នុងការផ្លាស់ប្តូរសាសនា។ ប៉ុន្តែ ការកាន់សាសនា មិនមែនដើម្បីបុណ្យសក្តិ ប្រាក់ខែ ឬ អំណោយផ្សេងៗ នោះទេ។ សាសនាខ្ពស់ណាស់ ថ្លៃណាស់ ថ្លៃជាងជីវិតទៅទៀត។ មុននឹងកាន់សាសនាណាមួយ គេគិតពិចារណាម៉ត់ចត់ណាស់... សាសនានោះឲ្យតម្លៃមនុស្សយ៉ាងម៉េច? មានឧត្តមគតិយ៉ាងម៉េច? ដឹកនាំជីវិតយ៉ាងម៉េច ដើម្បីឲ្យបានជួបនូវសន្តិភាពយ៉ាងខ្ពស់បំផុតគឺ និព្វាន។ គេគិតម៉ត់ចត់សព្វគ្រប់អស់ហើយ ទើបគេសម្រេចចិត្ត យកគោលសាសនានោះធ្វើជាមាគ៌ា ជាសាស្តា ជាពន្លឺនៃជីវិតរបស់គេ មិនមែនចូលកាន់សាសនា ព្រោះតែអំណោយនោះទេ។ បើកាន់សាសនា ព្រោះតែបានអំណោយ... តម្លៃនៃមនុស្ស វាបាត់អស់ទៅហើយ។

ម្យ៉ាងទៀត ការផ្លាស់សាសនា គឺការផ្លាស់ប្តូរវប្បធម៌ ប្រពៃណី ផងដែរ កាលអ្នកកាន់សាសនាថ្មីនៅមានគ្នាតិច គេនៅស្លូតគ្រាន់បើនៅឡើយទេ ពេលណាដែលគេមានកម្លាំងស្រដៀងគ្នា ពេលនោះហើយ ពួកគេបញ្ចេញចង្កូម។ ប្រទេសជាតិ ក៏កើតអន្តរធាន។ បរទេសអ្នកនាំសាសនាថ្មីចូលមកនោះ ក៏ជួយកូនចៅគេច្បាំងចេញមុខជាមួយនឹងយើងតែម្តង។ ប្រទេសជាតិដែលតូច ហើយគ្រាំគ្រាស្រាប់ទៅហើយ ក៏វិនាសសាបសូន្យត្រឹមណឹងឯងហោង៕

# វិធីផ្សាយ ពាហិរសាសនា របៀបថ្មី

វិធីផ្សាយរបៀបថ្មី មិនមែនបដិសេធរបៀបចាស់ចោលទាំងស្រុងទេ ចំណុចដែលនៅប្រើការបាន គេទុកប្រើការតទៅទៀត គ្រាន់តែមានការកែប្រែខ្លះ ឧទាហរណ៍៖ ពីដើមគេកាច(ប្រឆាំង) ឥឡូវគេស្លូត(វាយស្រប) ក្ដៅស៊ីរាក់ ត្រជាក់ស៊ីជ្រៅ គេចូលជួយគ្រប់វិស័យ ដែលគេអាចជួយបាន។ ពីដើមគេបេះយកម្ដងមួយៗ ឥឡូវគេស្រួបទាញយកទាំងអស់ គេមិនជួយតែគ្រហស្ថទេ គេជួយរហូតដល់ព្រះសង្ឃ ពេលខ្លះគេនាំគ្នាគេមកចូលរួមធ្វើបុណ្យតាមប្រពៃណីយើងផង ពេលខ្លះគេនិមន្តព្រះសង្ឃយើងចូលរួមប្រជុំ... ជាមួយគេក្នុងគោលបំណង...។ ពីដើមគេប្រើតែពាក្យប្រៀនប្រដៅក្នុងសាសនាគេ ឥឡូវគេយកពាក្យប្រៀនប្រដៅនិងពិធីក្នុងសាសនាយើងខ្លះទៅលាយឡំគ្នា ដើម្បីកុំឲ្យស្លែងចិត្តពេកដល់អ្នកដែលទើបចូលថ្មីផង ដើម្បីលើកកំពស់សាសនាគេផង នៅទីកន្លែងខ្លះ គេកែព្រះគេមានសម្លៀកបំពាក់ស្រដៀងនឹងឃ្លុំចីពរមានរស្មីស្រដៀងនឹងឆព្វណ្ណរង្សី របស់ព្រះពុទ្ធយើងដែរ (បែបចង់វាយស្មើ)។ សាសនាខ្លះទៀត អាចមានគម្រោងចែកទឹកចែកដីផង បើកាលទេសៈ ជួយសម្រួលឲ្យធ្វើដូចនោះបាន។ល។ គេចាត់ការមានសមរភូមិមុខ សមរភូមិក្រោយ គេធ្វើរបាយការណ៍ជារយៈៗ បញ្ជូនទៅថ្នាក់លើ ដើម្បីដឹងពីសភាពការនៃតំបន់នីមួយៗ ហើយពិចារណារកដំណោះស្រាយ ឲ្យសមស្របនិងទាន់ពេលវេលា។ ព្រះសង្ឃគេមានសេចក្ដីអត់ធន់ និងការតស៊ូកម្រិតខ្ពស់ណាស់ សូម្បីជីវិតក៏គេហ៊ានលះបង់ដើម្បីព្រះរបស់គេ។ នេះគ្រាន់តែជាសេចក្ដីសង្ខេប ប៉ុណ្ណោះ។

យើងជាពុទ្ធបរិស័ទ គប្បីជាមនុស្សល្អ ហើយឆ្លាត បើគេធ្វើល្អចំពោះយើង យើងត្រូវតែធ្វើល្អចំពោះគេវិញ បើគេមានមិត្តភាពល្អជាមួយយើង យើងត្រូវតែមានមិត្តភាពល្អជាមួយគេវិញ បើគេមានគុណលើយើង យើងត្រូវតែតបស្នងសងគុណគេវិញ ប៉ុន្តែ យើងត្រូវមានសតិ សម្បជញ្ញៈ កុំឲ្យធ្លាក់ខ្លួនទាបដល់ថ្នាក់យកសាសនាទៅដូរយករបស់បន្តិចបន្តួច ដូចជាយកមាសទៅដូរយកស្ពាន់ដូចនោះឡើយ។ ចំណែក ព្រះសង្ឃយើងត្រូវភ្ញាក់រលឹកឡើង ក្រោកឡើង បំពេញតួនាទីផ្ទាល់ខ្លួនឲ្យបានត្រឹមត្រូវផង ដឹកនាំពុទ្ធបរិស័ទឲ្យបដិបត្តិតាមតួនាទីរបស់ខ្លួនបានត្រឹមត្រូវល្អ និងទាន់ពេលវេលាផង៕

# តួនាទីរបស់ពុទ្ធបរិស័ទ

ពុទ្ធបរិស័ទ ៤ គឺ ៖ ភិក្ខុ ភិក្ខុនី (សាមណេរ) ឧបាសក ឧបាសិកា ត្រូវបំពេញតួនាទីរបស់ខ្លួនដូចតទៅនេះ៖

១.ត្រូវសិក្សាពុទ្ធសាសនា ឲ្យដឹងប្រវត្តិ និងគោលទ្រឹស្តីធំៗ ល្មមយកជាមាគ៌ាបដិបត្តិបាន សមតាមឋានៈរបស់ខ្លួន។

២.ត្រូវបដិបត្តិតាមពុទ្ធវចនៈឲ្យបានត្រឹមត្រូវ កុំយកអ្វីដែលទំនាស់នឹងពុទ្ធសាសនាមកបដិបត្តិលាយឡំគ្នា។

៣.ត្រូវជួយប្រាប់ពន្យល់ពុទ្ធវចនៈដល់បុគ្គលដទៃខ្លះផង កុំគិតយករួចខ្លួនតែម្នាក់ឯង។

៤.ត្រូវជួយទំនុកបម្រុងពុទ្ធសាសនា ដោយកម្លាំងកាយ កម្លាំងទ្រព្យ និងកម្លាំងសតិបញ្ញា តាមដែលអាចធ្វើបាន។

៥.ត្រូវរួមគ្នាថែរក្សា ការពារ និងផ្សព្វផ្សាយពុទ្ធសាសនាឲ្យអស់ពីសមត្ថភាព ក្នុងករណីចាំបាច់ សូម្បីជីវិតក៏ហ៊ានលះបង់។

៦.ត្រូវចេះគោរពគ្នា ចេះស្តាប់គ្នា ហើយសាមគ្គីគ្នាឲ្យបានជិតស្និទ្ធ ជុំវិញជាតិ និងសាសនា។

៧.ត្រូវមើល សុខទុក្ខគ្នា ត្រូវជួយទុក្ខធុរៈគ្នា និងត្រូវចូលរួមអភិវឌ្ឍន៍សង្គមសមតាមឋានៈខ្លួនឲ្យបានប្រសើរឡើង។

៨.ត្រូវប្រជុំគ្នារឿយៗ ដើម្បីរកដំណោះស្រាយបញ្ហា ផ្សេងៗ និងរិះរកមធ្យោបាយធ្វើឲ្យបានសុខ-ចំរើនឡើងថែមទៀត។

ព្រះសង្ឃមានតួនាទីសាងខ្លួន ឲ្យបានជាគម្រូល្អ ដល់គេផង មានតួនាទីដឹកនាំគេឲ្យបំពេញតួនាទីរបស់ពុទ្ធបរិស័ទនេះ ឲ្យបានត្រឹមត្រូវផង៕

# គ្រប់សាសនាត្រូវតែសាមគ្គី

## សាងសេចក្ដីសុខឲ្យមនុស្សលោក



មនុស្សលោកត្រូវការរំលត់ទុក្ខ ឬ និយាយមួយបែបទៀតថា ត្រូវការសេចក្ដីសុខ។ មនុស្សលោក ត្រូវការសាសនា ក៏ព្រោះតែដើម្បីរំលត់ទុក្ខ ឬដើម្បីសេចក្ដីសុខតែប៉ុណ្ណោះ ប្រសិនបើសាសនាមិនអាចជួយរឿងនេះបានទេ មនុស្សលោក ក៏មិនចាំបាច់ត្រូវការសាសនាដែរ ហេតុនេះសាសនា ត្រូវតែគិតគូឲ្យម៉ត់ចត់គ្រប់សាសនាត្រូវតែសាមគ្គី សាងសេចក្ដីសុខឲ្យមនុស្សលោក។

បើយើងសាមគ្គី សាងសេចក្ដីសុខឲ្យមនុស្សលោក ពិតមែន យើងត្រូវកុំចង់យកសាសនារបស់ខ្លួនមកគ្រប់គ្រងពិភពលោក ត្រូវកុំលើកសាសនារបស់ខ្លួន ហើយបន្ទុះបង្អាប់សាសនាដទៃ ត្រូវកុំប៉ែងជើង កុំកាច់ខ្នង កុំបៀតបៀន កុំបោកប្រាស់គ្នា។ យើងត្រូវតែមានមានសេចក្ដីស្មោះត្រង់ពិតប្រាកដ មានសេចក្ដីរាប់អានគ្នា ហើយនាំគ្នាយកសេចក្ដីល្អ ដែលមានក្នុងសាសនានោះៗមកជួយមនុស្សលោក។ យើងត្រូវ ឈប់លោភលន់ ឈប់ចង់បានមុខមាត់ ឈប់ចង់បានបរិស័ទ ឈប់ប្រកាន់ពួក បក្ស គណៈ និកាយ ផ្សាយសាសនា ដើម្បីរំលត់ទុក្ខ ឬ ដើម្បីសេចក្ដីសុខរបស់មនុស្សលោកតែប៉ុណ្ណោះ។ ក្រៅពីនេះមិនមានអ្វីដែលយើងគួរកាន់យកទេ៕

## កុំភ្លេចខ្លួន

មនុស្សមិនទាន់ឈប់លោភលន់ ចង់បានទ្រព្យធននិងមុខមាត់
បើយើងប្រហែសមុខជាភ្លាត់ ត្រូវប្រុងប្រយ័ត្នកុំភ្លេចខ្លួន។
ពិសេសរឿងជាតិ និងសាសនា ត្រូវថែរក្សាយ៉ាងខ្ជាប់ខ្ជួន
ការពារម៉ត់ចត់ និងមាំមួន ទើបបានរួចខ្លួនពីទុក្ខភ័យ៕

## ធម្មិកសូត្រ

## ប្រែជាកំណាព្យ

កាលណាហ្វូងគោ ហែលឆ្លងកាត់ទឹក
បើមេហ្វូងដឹក នាំហែលខុសផ្លូវ
កូនហ្វូងដែលនាំ គ្នាហែលតាមទៅ
តែងហែលខុសផ្លូវ ទៅតាមៗ គ្នា។
ដូចជាមនុស្ស នៅក្នុងសង្គម
បើលោកអ្នកធំ ដឹកនាំប្រជា
មិនគោរពច្បាប់ និង ព្រះធម្មា
ពលរដ្ឋគ្រប់គ្នា តែងយកតម្រាប់។
ប្រទេសជាតិ និង ពួកប្រជាជន
ទុក្ខសោកធ្ងរធ្ងន់ សល់សែនឱនអាប់
វិនាសសាបសូន្យ យ៉ាងរហ័សឆាប់
ព្រោះដើរខុសច្បាប់ គ្រប់ៗ គ្នាទៅ។
កាលណាហ្វូងគោ ហែលឆ្លងកាត់ទឹក
បើមេហ្វូងដឹក នាំហែលត្រូវផ្លូវ
កូនហ្វូងដែលនាំ គ្នាហែលតាមទៅ
តែងហែលត្រូវផ្លូវ ទៅតាមៗ គ្នា។
ដូចជាមនុស្ស នៅក្នុងសង្គម
បើលោកអ្នកធំ ដឹកនាំប្រជា

គោរពតាមច្បាប់ និង ព្រះធម្មា
ពលរដ្ឋគ្រប់គ្នា តែងយកតម្រាប់ ។
ប្រទេសជាតិ និង ពួកប្រជាជន
ចំរើនទ្រព្យធន និង កិត្តិស័ព្ទ
ថ្កុំថ្កើងរុងរឿង យ៉ាងរហ័សឆាប់
ព្រោះដើរត្រូវច្បាប់ គ្រប់ៗ គ្នាអើយ ៕

## ម្លូវារតាមជន្លង់

ម្លូវារតាមជន្លង់ វៀចឬត្រង់ទៅយ៉ាងណា
តាមតែជន្លង់វា ដែលទុកជាពំនឹងនោះ ៕

## ល្អពុម្ព ល្អព្រះ

ល្អពុម្ពល្អព្រះ តូចធំស្តើងក្រាស់ សមឬមិនសម
ស្រេចនៅលើពុម្ព ដែលជាងខិតខំ គិតគូឆ្លាក់ផ្សំ
ជាពុម្ពនោះឯង ។
ធ្វើពុម្ពបានល្អ ព្រះស្អាតបវរ ល្អល្អះចិញ្ចែង
ឆ្លាក់ពុម្ពយ៉ាងណា ព្រះយ៉ាងនោះឯង ដូចពុម្ពជាក់ស្តែង
គ្មានខុសត្រង់ណា ។
ម៉ែឪជាពុម្ព រីអ្នកដឹកនាំ ជាពុម្ពដូចគ្នា
កូនចៅប្រុសស្រី និងពួកប្រជា ជនទាំងអស់គ្នា
ធ្វើត្រាប់តាមពុម្ព ។
ហេតុនេះអ្នកនាំ ត្រូវតែខិតខំ ធ្វើឲ្យសមរម្យ
តាមគន្លងធម៌ និងច្បាប់ជាធំ ទើបគេនិយម
គោរពបូជា ៕

## សទ្ធា និង បញ្ញា

មានតែសទ្ធាអត់បញ្ញា ដូចធ្មេចនេត្រាដើរពេលយប់
គេចមិនផុតទេតែងជំពប់ ជឿច្រើនជ្រុលជ្រប់ចាញ់បោកគេ។
មានតែបញ្ញាអត់សទ្ធា ដូចអត់គ្នីគ្នាជួយក្នាញ់គ្នេរ
បញ្ញាម្នាក់ឯងតែងជ្រៀងជ្រេ ទេរទៅជាមិច្ឆាទិដ្ឋិ ៕

## ឧទ្ទិសកថា

យើងខ្ញុំ សូមឧទ្ទិសចំណែកបុណ្យកុសលនេះ ចំពោះលោកអ្នកដ៏មានគុណទាំងឡាយ មានគ្រូឧបជ្ឈាយាចារ្យ និងមាតាបិតាជាដើមផង ព្រមទាំងញាតិមិត្រទាំងឡាយផង។ សូមលោកអ្នកដ៏មានគុណមានមាតាបិតាជាដើមនោះ អនុមោទនាទទួលយក នូវឥដ្ឋមនុញ្ញផលជាទីគាប់ចិត្ត តាមសេចក្តីជ្រះថ្លារៀងៗខ្លួន កុំបីខាន៕

# ចប់